**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# សារលិខិត

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ក្នុងឱកាសប្រារព្ធទិវាអក្ខរកម្មជាតិ ០៨ កញ្ញា ២០២០

*-សូមថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ!*

*-សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី!*

*-សម្តេច ឯកឧត្តម លោកជំទាវ សមាជិក សមាជិកាព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល!*

*-ឯកឧត្តម លោកជំទាវ ព្រឹទ្ធាចារ្យ លោកតា លោកយាយ!*

*-លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្សជាទីស្រឡាញ់រាប់អាន និងបងប្អូនជនរួមជាតិទាំងអស់ជាទីគោរពស្នេហា !*

ក្នុងឱកាសដ៏មហោឡារិកនៃ *ទិវាអក្ខរកម្មជាតិ ០៨ កញ្ញា ២០២០* នេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ក្នុងនាមរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមសម្តែងនូវក្តីសោមនស្សរីករាយយ៉ាងក្រៃលែង និងសូមចូលរួមប្រកបដោយភាពស្និទ្ធស្នាលជាមួយបងប្អូនជនរួមជាតិ ស្របពេលដែលប្រជាជនកម្ពុជានៅទូទាំងប្រទេសកំពុងរស់នៅក្នុងបរិយាកាសនៃសុខសន្តិភាព និងការអភិវឌ្ឍ បន្ទាប់ពីរាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា ទទួលបាននូវការទុកចិត្តនិងគាំទ្រពីប្រជាពលរដ្ឋឱ្យបន្តបេសកកម្មដ៏ឧត្តុង្គឧត្តមជាប្រវត្តិសាស្ត្ររបស់ខ្លួន ជាមួយនឹងការប្តេជ្ញាចិត្តយ៉ាងមុតមាំឥតរាថយ និងកាន់តែស្វាហាប់ជាងពេលណាៗទាំងអស់ ក្នុងការបម្រើប្រជាពលរដ្ឋ ក៏ដូចជាក្នុងការពន្លឿនកិច្ចអភិវឌ្ឍន៍ និងជំរុញអនុវត្តកំណែទម្រង់កាន់តែស៊ីជម្រៅ និងទូលំទូលាយលើគ្រប់វិស័យឆ្ពោះទៅរកការកសាងអនាគតដ៏រុងរឿងមួយ ស្របតាមឆន្ទៈ និងបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់ប្រជាជនទូទៅនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

ទិវាអក្ខរកម្មជាតិត្រូវបានប្រារព្ធឡើងនៅថ្ងៃទី៨ ខែកញ្ញា ជារៀងរាល់ឆ្នាំ ប៉ុន្តែឆ្នាំនេះទិវានេះត្រូវបានអាក់ខានមិនបានប្រារព្ធធ្វើឡើង ដោយសារតែកម្ពុជាកំពុងប្រយុទ្ធប្រឆាំងនឹងការរាតត្បាតនៃជំងឺកូវីដ-១៩។ ទោះជាយ៉ាងណា ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំសូមថ្លែងនូវសារលិខិតថ្វាយ និងប្រគេនព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ ជូនជនរួមជាតិ សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកគ្រូ អ្នកគ្រូ បុគ្គលិកអប់រំ

ព្រមទាំងក្មួយៗ សិស្សានុសិស្សជាទីស្រឡាញ់ អំពីបុព្វហេតុដែលកម្ពុជាត្រូវយកចិត្តទុកដាក់លើការអភិវឌ្ឍធនធានមនុស្ស ដោយសាររាជរដ្ឋាភិបាលកម្ពុជាប្ដេជ្ញាជំរុញការលើកកម្ពស់ និងការកែលម្អជីវភាពរស់នៅរបស់ប្រជាពលរដ្ឋតាមរយៈការផ្ដល់ជូនដល់ស្រទាប់យុវជននូវការបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈប្រកបដោយគុណភាព ព្រមជាមួយ នឹងឱកាសទទួលបានការងារធ្វើ ការជួយកសិករក្នុងការពង្រឹងផលិតកម្ម និងការរកទីផ្សារលក់កសិផល។

ថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាទើបអនុម័តជាផ្លូវការនូវគោលនយោបាយជាតិស្ដីពី ការសិក្សាពេញមួយជីវិត ដែលមានគោលបំណង "ផ្ដល់ឱកាស និងគាំទ្រឱ្យប្រជាជនគ្រប់រូបទទួលបានការសិក្សាតាមគ្រប់រូបភាព គ្រប់ពេលវេលា គ្រប់ទីកន្លែង និងអាចប្រើប្រាស់ចំណេះដឹងតាមជំនាញដែលទទួលបាន ដើម្បីបង្កើនប្រសិទ្ធភាព គុណភាព ផលិតភាពការងារ និងប្រាក់ចំណូល ស្របតាមយុគសម័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន និងសង្គមពុទ្ធិ"។ ជាការអនុវត្តជាក់ស្ដែងមួយ នៅក្នុងអំឡុងពេលនៃការបង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំយុវជន និងកីឡានៅតែជានាឱ្យសិស្សានុសិស្ស និស្សិតនៅគ្រប់កម្រិតសិក្សាបានទទួលនូវសេវាអប់រំ តាមរយៈការអនុវត្តនូវការអប់រំតាមបែបឌីជីថល ឬការសិក្សាពីចម្ងាយតាមប្រព័ន្ធអេឡិចត្រូនិក និងការអប់រំពីចម្ងាយតាមបែបប្រពៃណី។ ជាមួយគ្នានេះ អ្នកសិក្សាក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធក៏បានបន្តសិក្សាតាមគ្រប់រូបភាព គ្រប់ពេលវេលា និងគ្រប់ទីកន្លែង ដោយសារក្រសួងអប់រំយុវជន និងកីឡាបានសហការជាមួយក្រសួងពាក់ព័ន្ធ និងដៃគូអភិវឌ្ឍក្នុងការរៀបចំផលិត និងផ្សព្វផ្សាយវីដេអូសម្រាប់ការបង្រៀនពីចម្ងាយ និងតាមប្រព័ន្ធអេឡិចត្រូនិកសម្រាប់កម្មវិធីអក្ខរកម្ម និងកម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ ព្រមទាំងមានការសម្របសម្រួលពីមន្ត្រីអប់រំក្រៅប្រព័ន្ធនៅតាមឃុំ សង្កាត់ អាជ្ញាធរដែនដី គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ និងគណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ ក្នុងគោលដៅជានាឱ្យដំណើរការរៀនសូត្ររបស់អ្នកសិក្សាមាននិរន្តរភាព។ ក្រសួងអប់រំយុវជន និងកីឡាបានសហការជាមួយក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងដៃគូអភិវឌ្ឍដាក់ឱ្យដំណើរការកម្មវិធីមួយដែលមានឈ្មោះថា « កម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋាន(**Basic Education Equivalency Program-BEEP**) » ដែលផ្ដល់ឱកាសដល់កម្មករ កម្មការិនីទាំងនៅក្នុង និងក្រៅប្រទេស មានលទ្ធភាពបន្តការសិក្សាតាមបែបអនឡាញ ឬតាមបែបឌីជីថល។ ក្រសួងអប់រំយុវជន និងកីឡាក៏បានសហការជាមួយក្រសួងមហាផ្ទៃ បើកថ្នាក់អក្ខរកម្មនៅតាមមណ្ឌលអប់រំកែប្រែ និងពន្ធនាគារនៅតាមរាជធានី ខេត្ត បានចំនួន ៣៨ ថ្នាក់ និងអ្នកជាប់ឃុំឃាំងទទួលបានការរៀនសូត្រសរុប ៨២៦ នាក់ ក្នុងគោលបំណងផ្ដល់ឱ្យពួកគាត់នូវចំណេះដឹង ជំនាញ មុខរបរ ការចេះអាន ចេះសរសេរ ចេះគិតលេខ និងចេះដោះស្រាយបញ្ហាដែលពាក់ព័ន្ធ បន្ទាប់ពីទទួលបានសិទ្ធិសេរីភាព និងការធ្វើសមាហរណកម្មទៅក្នុងសង្គមជាតិឡើងវិញ។

ក្រៅពីនេះ ក្រសួងអប់រំយុវជន និងកីឡាបានសហការជាមួយវិស័យឯកជននៅតាមរោងចក្រចំនួន ១១ រាជធានី ខេត្ត ដោយបានផ្ដល់ឱកាសឱ្យកម្មករ កម្មការិនី មានលទ្ធភាពចូលសិក្សាក្នុងកម្មវិធីអក្ខរកម្ម ដែលនឹងជួយឱ្យពួកគេអាចបំពេញការងារកាន់តែប្រសើរឡើងថែមទៀត និងជាមូលដ្ឋានគ្រឹះសម្រាប់ស្វែងរកអាជីពការងារដែលមានប្រាក់ចំណូលខ្ពស់ជាងមុន។

ទី៤-ប្រព័ន្ធផ្សព្វផ្សាយទាំងអស់រួមមាន បណ្ដាញសង្គម វិទ្យុ ទូរទស្សន៍ សារព័ត៌មាន ទស្សនាវដ្ដី ព្រឹត្តិបត្រព័ត៌មានរបស់រដ្ឋ និងឯកជន សូមជួយផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីអានុភាពនៃការងារអក្ខរកម្មដល់ប្រជាពលរដ្ឋយើង ដើម្បីឱ្យមានការយល់ដឹងកាន់តែទូលំទូលាយក្រោមប្រធានបទ « **អក្ខរកម្មជាមូលដ្ឋានគ្រឹះនៃការសិក្សាពេញមួយជីវិត** »។

ទី៥-ក្មួយៗជាសិស្ស និស្សិតតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ក្រុមយុវជនសហភាពសហព័ន្ធយុវជនកម្ពុជា ក្រុមយុវជនកាយរឹទ្ធិ និងក្រុមយុវជនកាកបាទក្រហមកម្ពុជា ត្រូវបន្តសកម្មចូលរួមជួយបង្រៀនដោយស្ម័គ្រចិត្តដល់អ្នកមិនចេះអក្សរនៅតាមថ្នាក់អក្ខរកម្ម និងមជ្ឈមណ្ឌលសិក្សាសហគមន៍ ដែលស្ថិតក្នុងមូលដ្ឋានរបស់ក្មួយៗរស់នៅ។ ចំណែកបងប្អូនជនរួមជាតិ ដែលជាមាតាបិតា ឬអ្នកអាណាព្យាបាល ក៏សូមជួយជំរុញបងប្អូន កូនចៅឱ្យបានចូលរៀនតាមសាលារៀនចំណេះទូទៅគ្រប់ៗគ្នា។ ដោយឡែកក្មួយៗ និងបងប្អូនដែលពុំទាន់ចេះអក្សរ ឬបោះបង់ការសិក្សាសូមបន្តខិតខំប្រឹងប្រែងរៀនសូត្រនៅតាមថ្នាក់អក្ខរកម្ម ថ្នាក់សមមូល ថ្នាក់ចូលរៀនឡើងវិញ មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិតដែលនៅជិតភូមិឋានរបស់ខ្លួន។

ទី៦-វត្តអារាម និងវិហារសាសនានានា ត្រូវចលនាព្រះសង្ឃ បព្វជិតសាសនា តាជី ដូនជី ចូលរួមជំរុញកម្មវិធីអក្ខរកម្មវិជ្ជាជីវៈឱ្យកាន់តែខ្លាំងក្លាថែមទៀត តាមរយៈការទេសនាអប់រំអំពីសារៈប្រយោជន៍នៃការរៀនសូត្រ អំពីសីលធម៌ និងលើកកម្ពស់វប្បធម៌រស់នៅក្នុងភាពជាពលរដ្ឋសកល។

ទី៧-ដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាលទាំងឡាយ ត្រូវបង្កើនកិច្ចសហការ និងពង្រឹងភាពជាដៃគូ តាមរយៈការជួយឧបត្ថម្ភគាំទ្រដល់កម្មវិធីអប់រំក្រៅប្រព័ន្ធ ជាពិសេសកម្មវិធីអក្ខរកម្មផ្សារភ្ជាប់នឹងការអប់រំវិជ្ជាជីវៈឱ្យមានដំណើរការល្អជាប់ជាប្រចាំ។

ទី៨-ប្រធានរោងចក្រ សហគ្រាស និងក្រុមហ៊ុនឯកជន សូមបន្តជួយជំរុញបើកថ្នាក់អក្ខរកម្មគួបផ្សំជាមួយថ្នាក់បំប៉នមុខជំនាញវិជ្ជាជីវៈផ្សេងៗដល់បងប្អូនកម្មករ កម្មការិនី ដើម្បីជាប្រយោជន៍របស់ពួកគេផង និងជាប្រយោជន៍ដល់ម្ចាស់រោងចក្រ សហគ្រាសផង។ ជាមួយនេះ យើងទាំងអស់គ្នាត្រូវចងចាំនូវពាក្យស្លោកថា « **មានអក្ខរកម្ម មានការគិតគូរ និងការសម្រេចចិត្តបានត្រឹមត្រូវ** » « **មានអក្ខរកម្មនាំឱ្យការអភិវឌ្ឍសហគមន៍កាន់តែរីកចម្រើន** » « **មានអក្ខរកម្ម មានសុខដុមជីវិតបុគ្គល គ្រួសារ និងសង្គម** »។

ជាថ្មីម្ដងទៀត ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំសូមថ្លែងអំណរគុណដល់គ្រប់ក្រសួង ស្ថាប័ន អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់សប្បុរសជននានា ព្រះសង្ឃ ចាស់ព្រឹទ្ធាចារ្យ បព្វជិតសាសនា និងប្រជាពលរដ្ឋទាំងអស់ ដែលបាន និងកំពុងជួយឧបត្ថម្ភគាំទ្រយ៉ាងសកម្មដល់ការងារអក្ខរកម្មនាពេលកន្លងមក ។ ទូលព្រះបង្គំខ្ញុំព្រះករុណាខ្ញុំសង្ឃឹមថា ការប្រារព្ធទិវាអក្ខរកម្មជាតិ ០៨ កញ្ញា ២០២០ នឹងបន្តដាស់ស្មារតីយើងទាំងអស់គ្នាឱ្យចូលរួមក្នុងការងារនេះកាន់តែសកម្មថែមទៀត។

សមិទ្ធផលនៃការអនុវត្តកម្មវិធីអក្ខរកម្មដែលសម្រេចបាននេះ បានបង្ហាញឱ្យឃើញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងការចូលរួមគាំទ្រយ៉ាងសកម្មពីសំណាក់អ្នកពាក់ព័ន្ធនិងដៃគូអភិវឌ្ឍនានា ជាពិសេសកិច្ចខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ មន្ត្រីរាជការ ព្រះសង្ឃ បញ្ញាវន្ត ម្ចាស់រោងចក្រ សហគ្រាស សិស្ស និងនិស្សិតទូទាំងប្រទេស។

នៅឆ្នាំ ២០២០ នេះ ទិវាអក្ខរកម្មជាតិ ៨ កញ្ញា ត្រូវបានប្រារព្ធឡើងក្រោមប្រធានបទ « **អក្ខរកម្មជាមូលដ្ឋានគ្រឹះនៃការសិក្សាពេញមួយជីវិត** »។ ទស្សនាទានរបស់ប្រធានបទនៅឆ្នាំនេះ មិនសំដៅត្រឹមតែការរៀនអក្សរ និងលេខនព្វន្តប៉ុណ្ណោះទេ ប៉ុន្តែបានគិតគូរដល់ឱកាសសម្រាប់យុវជន និងពលរដ្ឋគ្រប់វ័យរបស់យើងអាចទទួលបានចំណេះដឹង ចំណេះធ្វើ សហគ្រិនភាព ជំនាញមុខរបរ និងនវានុវត្តគ្រប់ផ្នែក គ្រប់វិស័យ ជាពិសេសអក្ខរកម្មបច្ចេកវិទ្យា និងអក្ខរកម្មឌីជីថលដែលសព្វថ្ងៃកំពុងមានការរីកចម្រើនយ៉ាងឆាប់រហ័ស។

*ជនរួមជាតិជាទីស្នេហា!*

ក្នុងបរិការណ៍នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ ២០៣០ និងដើម្បីផ្សារភ្ជាប់ការងារអក្ខរកម្ម **ជាមូលដ្ឋានគ្រឹះនៃការសិក្សាពេញមួយជីវិត** ជាពិសេសឈានទៅសម្រេចបាននូវគោលដៅប្រែក្លាយពលករដែលប្រើកម្លាំងសុទ្ធសាធទៅជាការប្រើប្រាស់ជំនាញស្របតាម « *យុទ្ធសាស្ត្រកំណើនថ្មី* » របស់កម្ពុជា ទូលព្រះបង្គំខ្ញុំព្រះករុណាខ្ញុំសូមអំពាវនាវដល់ស្ថាប័នជាតិ អន្តរជាតិ សហគមន៍ និងពលរដ្ឋគ្រប់រូបសូមយកចិត្តទុកដាក់ខ្ពស់ជាបន្តទៀតដល់ការងារអក្ខរកម្ម ក៏ដូចជាការងារអប់រំទាំងនៅក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ។

ក្នុងស្មារតីនេះ ដើម្បីបន្តចូលរួមលើកកម្ពស់ការងារអក្ខរកម្មនៅកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមអំពាវនាវដូចតទៅ៖

**ទី១**-ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវរៀបចំគោលនយោបាយ ក្របខណ្ឌច្បាប់ លិខិតបទដ្ឋាន និងយន្តការចាំបាច់ ដើម្បីដឹកនាំ គ្រប់គ្រង និងអនុវត្តឱ្យមានប្រសិទ្ធភាព និងគុណភាព ពាក់ព័ន្ធនឹងការសិក្សាពេញមួយជីវិតសម្រាប់ប្រជាពលរដ្ឋគ្រប់រូប និងស្របទៅនឹងបរិការណ៍ថ្មីនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

**ទី២**-ក្រសួង ស្ថាប័ន គ្រឹះស្ថានសិក្សា មណ្ឌលសិក្សា ទីវត្តអារាមទាំងអស់ត្រូវបង្កើតកម្មវិធីអប់រំ កម្មវិធីសិក្សាពេញមួយជីវិតទាំងផ្នែកអក្ខរកម្ម ទាំងផ្នែកវិជ្ជាជីវៈ ឱ្យកាន់តែសម្បូរបែប និងមានភាពទន់ភ្លន់ឆ្លើយតបនឹងតម្រូវការអ្នកសិក្សា ទាំងសេវាអប់រំក្នុងប្រព័ន្ធ អប់រំក្រៅប្រព័ន្ធ និងអប់រំមិនផ្លូវការដល់ប្រជាពលរដ្ឋគ្រប់រូប។

**ទី៣**-អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវយកចិត្តទុកដាក់ចូលរួមគាំទ្រឱ្យបានខ្លាំងក្លាថែមទៀត ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ មណ្ឌលសិក្សា និងជំរុញលើកទឹកចិត្តដល់ប្រជាពលរដ្ឋ ដែលមិនបានរៀនសូត្រ ឬបោះបង់ការសិក្សាឱ្យមានឱកាសទទួលបានការរៀនសូត្រជាថ្មី តាមរយៈថ្នាក់រៀនអប់រំក្រៅប្រព័ន្ធតាមគ្រប់រូបភាព ជាពិសេសត្រូវខិតខំបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋ ដែលជាជនមានពិការភាពឱ្យទទួលបានការសិក្សារៀនសូត្រ ប្រកបដោយសមភាព និងបរិយាបន្ន។

ជាទីបញ្ចប់ ទូលព្រះបង្គំជាខ្ញុំ ព្រះករុណាខ្ញុំសូមថ្វាយព្រះពរ និងប្រគេនពរជូនសម្តេចព្រះសង្ឃរាជ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងជូនពរបងប្អូនជនរួមជាតិ សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ បុគ្គលិកអប់រំ ព្រមទាំងក្មួយៗជាទីស្រឡាញ់ទាំងអស់ សូមសមប្រកបដោយពុទ្ធពរបួនប្រការគឺ *អាយុ វណ្ណៈ សុខៈ និងពលៈ* កុំបីឃ្លៀងឃ្លាតឡើយ។

*ថ្ងៃ ចន្ទ ៥រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤*

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០*

**ហ៊ុន សែន**